Capacity Development for Education for All
The CapEFA Programme

United Nations Educational, Scientific and Cultural Organization

សុន្ទរកថាបើក
លោក រស់ សុវាចា
តំណាងលោកស្រី អាន ឡឺមែស្រ្ត តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា
ក្នុងពិធីសម្ពោធ មជ្ឈមណ្ឌលសិក្សាសហគមន៍រហាល ខេត្តសៀមរាប
**ថ្ងៃទី ២០ កុម្ភៈ ២០១៥**

**ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**
**ឯកឧត្តម ឃឹម ប៊ុនសុង អភិបាលខេត្តសៀមរាប**
**លោក** Noboru Nouguchi **អគ្គនាយកអង្គការអិនអេហ្សយូអេជេ ប្រចាំទីក្រុងតូក្យូ ប្រទេសជប៉ុន**
**លោក លោកស្រី សមាជិកគណកម្មការ មសស រហាល និងភ្ញៀវកិត្តិយសជាទីមេត្រី**

យើងកំពុងតែប្រារព្ធពិធីសម្ពោធមជ្ឈមណ្ឌលសិក្សាសហគមន៍ (មសស) រហាល។ នេះជា មសស ទី ១៣ ហើយដែលគាំទ្រដោយអង្គការអិនអេហ្សយូអេជេ។ ក្នុងនាមអង្គការយូណេស្កូ ខ្ញុំសូមសំដែងនូវការអបអរសាទរជាមួយនឹងក្រុមការងាររបស់អង្គការអិនអេហ្សយូអេជេ ដែលបានបន្តនូវភាពជោគជ័យនៃដំណើរការ មសស នៅក្នុងប្រទេសកម្ពុជា។ ដើម្បីជួយគាំទ្រដល់តម្រូវការអប់រំរបស់ប្រទេសជាសមាជិក ជាពិសេសក្នុងការធ្វើអោយសម្រេចបានគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា និងការអប់រំពេញមួយជីវិត អង្គការយូណេស្កូបានដាក់ចេញនូវកម្មវិធីអភិវឌ្ឍសមត្ថភាពអប់រំសម្រាប់ទាំងអស់គ្នា (CapEFA) នៅក្នុងប្រទេសជាអាទិភាពមួយចំនួនក្នុងសាកលលោក។ មសស គឺជាផ្នែកមួយទទួលបានការយកចិត្តទុកដាក់ ពីប្រទេសជាច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយអង្គការយូណេស្កូក៏បានជួយកិច្ចការនេះ ដោយសហការជាមួយប្រទេសទាំងនោះ ដៃគូបច្ចេកទេសវិស័យឯកជន និងភ្នាក់ងារសង្គមស៊ីវិល។

នៅក្នុងឱកាសនៃការប្រារព្ធពិធីនេះ ខ្ញុំសូមរួមចំណែកដោយនិយាយពីតួនាទីរបស់អក្ខរកម្មនៅក្នុងការពង្រឹងសេដ្ឋកិច្ចកម្ពុជា តាមរយៈ មសស។ ហេតុនេះ ខ្ញុំនឹងលើកឡើងនូវគំនិតមួយចំនួនអំពីទំនាក់ទំនង មសស និងការដំណើរការថ្នាក់អក្ខរកម្ម។ នៅក្នុងឆ្នាំ២០១៥នេះ ការងារអក្ខរកម្មដែលជាផ្នែកមួយនៃអនុវិស័យអប់រំក្រៅប្រព័ន្ធ ទទួលបានការយកចិត្តទុកដាក់បំផុត ពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ដូចដែលបានលើកឡើងនៅក្នុង *សៀវភៅជំនួយសម្រាប់ការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍* ដែលបានផលិត ដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការគាំទ្រពីអង្គការយូណេស្កូ មសស នឹងដើរតួនាទី ជាទីកន្លែងនៅមូលដ្ឋានសម្រាប់ប្រជាជនគ្រប់វ័យក្នុងសហគមន៍ ដូចជា ជនពេញវ័យ យុវជន និងកុមារ ដើម្បីចូលរួមរៀនសូត្រតាមគ្រប់រូបភាព ដូចជាតាមរយៈកម្មវិធីអក្ខរកម្ម និងអប់រំបន្ត។ កម្មវិធី CapEFA របស់អង្គការយូណេស្កូនៅកម្ពុជា បានធ្វើកិច្ចសហការជាមួយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន

និងកីឡា (អយក) ចាប់តាំងពីឆ្នាំ២០១០។ ក្រសួង អយក និងអង្គការយូណេស្កូ បានឯកភាពគ្នាជាគោលការណ៍ នៅក្នុងការអនុវត្ត យុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥ នៅកម្ពុជា ដូចដែលបានគ្រោងឡើងនៅក្នុង ផែនការពន្លឿនការងារអក្ខរកម្មរបស់ប្រទេស (CLAP) ឆ្នាំ២០១៣-២០១៥។ យុទ្ធនាការអក្ខរកម្មជាតិមានគោលបំណង ដើម្បីអោយប្រទេសកម្ពុជាអាចសម្រេចបានគោលដៅអប់រំសម្រាប់ទាំងអស់គ្នា (៨៥,៥% នៅចុងឆ្នាំ២០១៥) និងរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤-២០១៨។

ចំពោះអ្នកមិនចេះអក្សរ អក្ខរកម្មគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់កែលម្អគុណភាពនៃជីវិត និងរួមចំណែកដល់ការធ្វើអោយប្រសើរឡើងក្នុងជីវភាពរស់នៅរបស់ពួកគេ។ អក្ខរភាពគឺមិនសំដៅត្រឹមតែទៅលើការចេះអាន និងសរសេរនោះទេ ប៉ុន្តែវាស្តែងឡើងតាមរយៈបុគ្គលនីមួយៗ នៅក្នុងការប្រើប្រាស់បំណិនដែលទទួលបានទាំងនេះ ដើម្បីចូលប្រលូកក្នុងសង្គមប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត អក្ខរភាពមិនត្រឹមតែមានឥទ្ធិពលលើលទ្ធភាពចូលរួមរបស់អនក្ខរជននៅក្នុងសកម្មភាពសង្គម និងការយល់ដឹងពីបញ្ហានានានៅក្នុងសង្គមប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្តល់ជាមូលដ្ឋានគ្រឹះមួយក្នុងការស្វែងយល់ពីជំនាញចាំបាច់នានាដែលជា តម្រូវការរបស់ទីផ្សារការងារ។ ជាឧទាហរណ៍ អ្នកមានបំណិនអក្ខរកម្មជ្រៅជ្រះអាចមានលទ្ធភាពខ្ពស់នៅក្នុងការមានការងារល្អ រក្សាបាននូវស្ថានភាពជីវិតរស់នៅដ៏ប្រសើរ និងទទួលបាននូវសេវាសាធារណៈបានកាន់តែល្អប្រសើរ។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានការរីកចម្រើនគួរអោយកត់សំគាល់នូវក្នុងទសវត្សចុងក្រោយនេះ ប៉ុន្តែអក្ខរភាពនូវតែជាបញ្ហាប្រឈមដ៏ចម្បងមួយនៅឡើយ។ ផ្អែកលើរបាយការណ៍ជំរឿនប្រជាជនឆ្នាំ២០០៨ មានប្រជាជនប្រមាណតែ៧៧,៦%ប៉ុណ្ណោះដែលជាអក្ខរជន ក្នុងខណៈដែលចំណែកថវិកាសម្រាប់វិស័យអប់រំក្រៅប្រព័ន្ធនៅមានកម្រិតទាបផងដែរ។

ក្នុងគំនិតផ្តួចផ្តើម និងការគាំទ្រពីអង្គការយូណេស្កូ ក្រសួងបានផលិតផែនទីចំនួន ៥០០ ដែលជាផែនទីបានបង្ហាញពីអត្រាអក្ខរកម្ម និងចំនួនអនក្ខរជន សម្រាប់ថ្នាក់ជាតិ ខេត្ត និងស្រុក ដោយបានបង្ហាញពីស្ថានភាពទិន្នន័យអក្ខរកម្ម និងអនក្ខរជនតាមភូមិ ដែលជាមូលដ្ឋានសម្រាប់ការវិភាគ និងការកសាងផែនការ។ ជាងនេះទៀត ក្រោមការគាំទ្រកម្មវិធី CapEFA របស់អង្គការយូណេស្កូ ក្រសួងបានអនុម័តផែនការពន្លឿនអក្ខរកម្មរបស់ប្រទេស ធ្វើជាគោលសម្រាប់កំណត់ទីតាំងថ្នាក់អក្ខរកម្ម និងជាមគ្គុទ្ទេសនៅក្នុងដំណើរការយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ដើម្បីបំពេញបន្ថែមទៅលើកិច្ចប្រឹងប្រែងរបស់ក្រសួង អយក ខ្ញុំសូមឆ្លៀតយកឱកាសនេះអំពាវនាវអោយមានការគាំទ្រទូទាំងប្រទេសដល់យុទ្ធនាការអក្ខរកម្មជាតិ ដែលមានគោលដៅផ្តល់ថ្នាក់អក្ខរកម្មនៅតាមទីតាំងនានា រួមទាំង មសស និងសាលាបឋមសិក្សា។ អង្គការយូណេស្កូ និងក្រសួង អយក ត្រូវការកៀរគរធនធានសរុប រួមមានការគាំទ្រពីក្រសួងពាក់ព័ន្ធ (ដូចជា ក្រសួងមហាផ្ទៃ និងក្រសួងផ្សេងទៀត) និងវិទ្យាស្ថាននានា (ដូចជា វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងវិទ្យាស្ថានផ្សេងទៀត) ផ្នែកឯកជន សង្គមស៊ីវិល ស្ថាប័នសាធារណៈ និងសហគមន៍អន្តរជាតិ។ នៅខេត្តសៀមរាប អង្គការអិនអេហ្សយូអេជេ អាចចូលរួមចំណែកក្នុងយុទ្ធនាការ

អក្ខរកម្មជាតិ តាមរយៈការកៀរគរអង្គការNGOs ផ្សេងទៀតអោយដំណើរការថ្នាក់អក្ខរកម្មអោយបានកាន់តែច្រើនឡើង។ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការNGOs នានាដែលមានផែនការដំណើរការថ្នាក់អក្ខរកម្មនៅឆ្នាំ ២០១៥នេះ។

ដើម្បីគាំទ្រដល់យុទ្ធនាការអក្ខរកម្មជាតិ ការចូលរួមរបស់មន្ត្រីអប់រំស្រុក និងអប់រំខេត្តគឺដើរតួនាទីយ៉ាងសំខាន់។ ជាឧទាហរណ៍ ប្រធានឃុំ ស្រុក អាចរួមចំណែកគាំទ្រយុទ្ធនាការនេះ តាមរយៈការផ្តល់ព័ត៌មានស្តីពីការចូលរៀន ដល់គ្រូ និងសិស្សអក្ខរកម្ម ។ សម្រាប់យុទ្ធនាការនេះ ក្រសួង អយក និង អង្គការយូណេស្កូ បានគ្រោងផែនការថ្នាក់អក្ខរកម្មចំនួន ៣៦៨៥ថ្នាក់។ ក្រសួងនឹងប្រើប្រាស់គ្រូបឋមសិក្សាចំនួន ២៥៥៨ និងគ្រូអក្ខរកម្ម ១១២៧នាក់ សម្រាប់ដំណើរការថ្នាក់អក្ខរកម្មនេះ។ គ្រូបង្រៀនទាំងនេះគឺជាកត្តលិករួមចំណែកធ្វើអោយយុទ្ធនាការនេះទទួលបានជោគជ័យ។ ខ្ញុំសូមឆ្លៀតឱកាសនេះជម្រាបជូនជាព័ត៌មានថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីផ្សព្វផ្សាយយុទ្ធនាការអក្ខរកម្មជាតិ ដែលនឹងប្រារព្ធនៅថ្ងៃទី ០២ មីនា ២០១៥ នៅ វិទ្យាស្ថានជាតិអប់រំ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

មុននឹងបញ្ចប់ អនុញ្ញាតអោយខ្ញុំយកឱកាសនេះអរគុណអង្គការអិនអេហ្វយូអេជេ ចំពោះសកម្មភាពល្អៗទាំងអស់ក្នុងការបន្តពង្រឹង មសស ដែលមានស្រាប់ ក៏ដូចជា មសស ទើបបង្កើតថ្មី ដើម្បីជាប្រយោជន៍ដល់ប្រជាជនជាច្រើនក្នុងសហគមន៍ក្នុងខេត្តសៀមរាប។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ អង្គការយូណេស្កូប្រចាំទីក្រុងភ្នំពេញ បានចាត់ទុកថាអង្គការអិនអេហ្វយូអេជេ គឺជាដៃគូសហការដ៏សំខាន់មួយ។ ជាងនេះទៀត ខ្ញុំសូមសំដែងនូវអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍តាមរយៈ មសស។ ក្នុងគោលបំណងពង្រឹងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាតាមរយៈ មសស ចាំបាច់ត្រូវពង្រឹងការកសាងផែនការប្រចាំឆ្នាំរបស់ មសស ដោយផ្អែកលើមូលដ្ឋានជាក់ស្តែង។ នៅក្នុងស្មារតីនេះ អង្គការយូណេស្កូសូមធានាអះអាងសារជាថ្មីនូវការបន្តការប្តេជ្ញារបស់ខ្លួន ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង។ ហើយខ្ញុំនឹងបន្តសហការជាមួយក្រសួងនៅក្នុងការជួយអោយអ្នកសិក្សាប្រមាណ ១សែននាក់ ក្លាយជាអក្ខរជននៅចុងឆ្នាំ ២០១៥។

ជាថ្មីម្តងទៀត សូមសំដែងនូវការអបអរសាទរជាមួយនឹងក្រុមការងាររបស់អង្គការអិនអេហ្វយូអេជេ នៅក្នុងការសម្ពោធដាក់អោយដំណើរការ មសស រហាលនេះ។

សូមអរគុណ!